ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖ ០០១៤/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍

## សូមទម្លាក់ចោលបទចោទប្រកាន់ និងដោះលែង លោក រ៉ុង ឈុន

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមថ្កោលទោសយ៉ាងដាច់អហង្កា ចំពោះអាជ្ញាធររដ្ឋាភិបាល ដែលបានចាប់ខ្លួនលោក **រ៉ុង ឈុន** តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងជាប្រធានសហភាពសហជីពកម្ពុជា នៅល្ងាចថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ «*ទាក់ទងនឹងការបំភ្លៃការពិតលើបញ្ហាព្រំដែន ដែលជាបទល្មើសជាក់ស្តែង គឺបទល្មើសញុះញង់បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា*»។

ការចាប់ខ្លួននេះ គឺជាការរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងធ្ងន់ធ្ងរ ត្រង់មាត្រា៤១ កថាខណ្ឌទី១ ចែងថា «*ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ*»។ ជាងនេះទៀត គឺជាការរំលោភលើសេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៩ ចែងថា «*មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិ ដោយគ្មានការរជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួលនិងការផ្សព្វផ្សាយព័តមាន និងគំនិតនានា ដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ*»។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមអំពាវនាវយ៉ាងទទូចដល់តុលាការកម្ពុជា ទម្លាក់ចោលបទចោទប្រកាន់ និងដោះលែងលោក **រ៉ុង ឈុន** ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**

2402 24TH ST SE, WASHINGTON, DC 20020 | TEL: (202) 430-5503 | EMAIL: INFO@SMD2.NET | WWW.SMD2.NET